ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ...........ន. គ. ស .......

ថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ដែលមានជំនាញក្នុងការបង្រៀន

**និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)** គឺជាស្ថាប័នតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន **ន.គ.ស.** បានដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មរយៈពេល១០ឆ្នាំ (២០២១ - ២០៣០) ។ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់ការអភិវឌ្ឍន៍ និងការកសាងសមត្ថភាពមន្ត្រី ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងផែនការអភិវឌ្ឍន៍ស្ថាប័ន **ន.គ.ស.** ត្រូវការជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីផ្តល់សេវាបណ្តុះបណ្តាលជំនាញ “**ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង**”។

ក្នុងន័យនេះ **ន.គ.ស.** សូមប្រកាសជ្រើសរើសក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ដែលមានគុណវុឌ្ឍិ ដូចខាងក្រោម÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាលដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល÷

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មពេញលេញ
- មានបទពិសោធន៍លើការបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងមានរយៈពេលយ៉ាងតិច៥ឆ្នាំ
- ធ្លាប់បានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

### ២. លក្ខខណ្ឌយោងការងារ

- បណ្តុះបណ្តាលមន្ត្រី **ន.គ.ស.** ឱ្យមានការយល់ដឹងស៊ីជម្រៅលើភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- រៀបចំផែនការក្នុងការបង្រៀនទាក់ទងទៅនឹងជំនាញ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង ដែល **ន.គ.ស.** បានតម្រូវ
- រៀបចំការវាយតម្លៃ និងមតិកែលម្អ។

### ៣. តម្លៃ

កម្រៃសម្រាប់ការបណ្តុះបណ្តាល “ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង” គឺបើកចំហរសម្រាប់ការចរចា។

### ៤. រយៈពេលនៃការបណ្តុះបណ្តាល

ការបណ្តុះបណ្តាល “ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង” មានរយៈពេលចន្លោះពី ៣-៥ថ្ងៃ។ កិច្ចសន្យានៃការផ្តល់សេវាមួយនេះ នឹងត្រូវបង្កើតឡើងរវាង **ន.គ.ស.** ជាមួយនឹងក្រុមហ៊ុន ឬគ្រឹះស្ថានបណ្តុះបណ្តាល ដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

**៥. ការដាក់ពាក្យ**

ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ សូមផ្ញើសេចក្តីចំណាប់អារម្មណ៍មក **ន.គ.ស** តាមរយៈអ៊ីម៉ែល t.satya@acar.gov.kh និង h.sokunthea@acar.gov.kh ត្រឹមថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០២៤ ដោយដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ÷ ០៦៩ ៧៨៣ ៩៣៦/ ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**